# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ ឯក ព្រឹង ភេទស្រី អាយុ៦៨ឆ្នាំ
## ជំនាន់ខ្មែរក្រហម“ប្រជាជនចាស់”
## រស់នៅភូមិភូមិចង្វារៀល ឃុំពាម ស្រុកសាមគ្គីមានជ័យ កំពង់ឆ្នាំង ។
## ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី

ដានី : លោកយាយដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកយាយ លោកឈ្មោះពេញ ឈ្មោះអីដែរ?

ព្រឹង : ខ្ញុំឈ្មោះព្រឹង ។

ដានី : ឈ្មោះអីព្រឹង?

ព្រឹង : ឯង ព្រឹង ។

ដានី : ឯងព្រឹង?

ព្រឹង : ចាស ។

ដានី : លោកយាយអាយុប៉ុន្មានហើយ?

ព្រឹង : អាយុ៦៨ ។

ដានី : លោកស្រុកកំណើតលោកយាយនៅណាទៅ ភូមិអី ឃុំអីទៅ?

ព្រឹង : ស្រុកដែលខ្ញុំកើត ។

ដានី : បាទ ។

ព្រឹង : ស្រុកខ្ញុំកើតគេហៅភូមិឡុង ខ្សាច់ពូនហ្នឹង ខ្ញុំកំណើតកើតជាខ្ញុំនៅនោះ ។

ដានី : ចឹងនៅភូមិឡុង ស្ដេចពូនណែស?

ព្រឹង : ខ្សាច់ពូន ។

ដានី : ភូមិឡុងខ្សាច់ពូនចឹងគេហៅ?

ព្រឹង : ភូមិហ្នឹងគេហៅឡុងៗចឹងវាជាប់ហ្នឹងខ្សាច់ពូនហ្នឹង ដាក់ចឹងទៅ ។

ដានី : បាទ!ហើយឃុំអីគេនៅហ្នឹង?

ព្រឹង : ឃុំវាលពង់ឬគេហៅឃុំអី អើយខ្ញុំមិនសូវស្គាល់ទេ ។

ដានី : បាទ ។

ព្រឹង : ដឹងៗតែខេត្ត ។

ដានី ៖ វាលពង់?

ព្រីង ៖ ដឹងអីទេ ។

ដានី ៖ វាលពង់ឬវាលពន់?

ព្រីង ៖ ដឹងវាលពង់ដឹងវាលពន់ ។

ដានី ៖ បាទ! នៅស្រុកអីគេ នៅខាងហ្នឹង?

ព្រីង ៖ ស្រុកខដុង ។

ដានី ៖ ស្រុកខដុង?

ព្រីង ៖ ស្រុកខដុង ខេត្តកំពង់ស្ពឺ "អ្នកនៅជិតនិយាយ" ។

ដានី ៖ កំពង់ស្ពឺបាទ! ហើយគ្រួសារលោកយាយគាត់ឈ្មោះអី លោកតា?

ព្រីង ៖ គាត់ឈ្មោះ មុំ មូល ។

ដានី ៖ ឈ្មោះមុំ មូល គាត់អាយុប៉ុន្មានដែរ?

ព្រីង ៖ គាត់អាយុ៦៩ ។

ដានី ៖ គាត់អាយុ៦៩ ស្រុកកំណើតគាត់នៅណាដែរ?

ព្រីង ៖ ស្រុកកំណើតគាត់នៅប្រាបកន្ទួត ហុងគ្នោត ។

ដានី ៖ ភូមិអីគេហ្នឹង?

ព្រីង ៖ ភូមិប្រាបកន្ទួត "អ្នកជិតខាងនិយាយ" ឃុំពាម ស្រុកសាមគ្គីមានជ័យ ។

ដានី ៖ ប្រាបកន្ទួត?

ព្រីង ៖ អ្នកជិតនិយាយ "ភូមិប្រាបកន្ទួត" ។

ដានី ៖ ឃុំពាមស្រុកសាមគ្គីមានជ័យ លោកយាយមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ព្រីង ៖ ខ្ញុំកូនច្រើនណាស់ ៨នាក់ ។ អ្នកជិតនិយាយ គាត់រាប់ទាំងអស់ បាត់តែមួយទេ ។

ដានី ៖ កូន៨នាក់ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ព្រីង ៖ ប្រុសពីរស្រី៦ ។

ដានី ៖ ប្រុសពីរ ស្រី៦បាទ! ចុះលោកយាយថាបាត់ហ្នឹងកូនស្រីឬកូនប្រុស?

ព្រីង ៖ បាត់កូនស្រី ។

ដានី ៖ បាត់កូនស្រី?

ព្រីង ៖ ចាស ។

ដានី ៖ បាត់យ៉ាងម៉េចលោកយាយអាចរៀបរាប់បានទេ?

ព្រឹង ៖ បាត់ហ្នឹងដំបូងវានៅរៀនកន្លែងគេបង្រៀនហ្នឹងណាស់ កាលនោះគេមានគ្រូគេបង្រៀន គេបង្រៀនចឹងទៅវាហាត់ខាងសិល្បៈ ដល់ហាត់ខាងសិល្បៈហ្នឹង ចេះតែទៅៗរហូតចឹងទៅ ។

ដានី ៖ អរ! ។

ព្រឹង ៖ បាត់រកលែងឃើញ ។

ដានី ៖ បាទ ។

ព្រឹង ៖ តាមគេតាមឯងចឹងទៅ ។

ដានី ៖ ចឹងលោកយាយការជាមួយលោកតាហ្នឹងតាំងពីកាល?

ព្រឹង ៖ អត់ចាំទេ ។

ដានី ៖ តាំងពីជំនាន់ណា?

ព្រឹង ៖ យូរដែលហើយ ពិបាកចាំឆ្នាំទៀតណាស់ ដឹងឆ្នាំ៦០ប៉ុន្មាន ខ្ញុំភ្លេចអស់ហើយ ។

ដានី ៖ ឆ្នាំ៦០ជាង?

ព្រឹង ៖ ៦០ជាង ។

ដានី ៖ ដល់ពេលការហើយលោកយាយផ្លាស់មកនៅណាដំបូង?

ព្រឹង ៖ ចាំមើលណាស់ កំណើតកើតជាខ្ញុំនៅអីកើតនោះណាស់ ។

ដានី ៖ បាទ ។

ព្រឹង ៖ រួចដល់ខ្ញុំម៉ែខ្ញុំ ពុកខ្ញុំហ្នឹងគាត់នៅស្រុកហ្នឹងហើយបានម្ដាយខ្ញុំនៅណុង ។

ដានី ៖ បាទ ។

ព្រឹង ៖ ដល់ពេលចឹងគាត់នៅណុងពិបាករកស៊ីពេក កាលហ្នឹងចោរវាប្លន់នោះ សំបក់ឥស្សរៈហ្នឹង ។

ដានី ៖ បាទ ។

ព្រឹង ៖ ដល់ចឹងគាត់មកនៅហ្នឹងវិញ ។

ដានី ៖ នៅណា?

ព្រឹង ៖ នៅហ្នឹង នៅភូមិតាំងស្វាយចាស់ហ្នឹង ។

ដានី ៖ ភូមិតាំងស្វាយចាស់?

ព្រឹង ៖ ចាស ។

ដានី ៖ ភូមិតាំងស្វាយឃុំអីហ្នឹង?

ព្រឹង ៖ ហ្នឹងភូមិតាំងស្វាយពីដើមនៅអមមាត់ស្ទឹង គេហៅភូមិតាំងស្វាយ ។

ដានី ៖ ឃុំអី?

ព្រឹង ៖ ឃុំពាម ។

ដានី : ស្រុកអីគេ?

ព្រឹង : កាលនោះគេហៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ដានី : អរចឹង?

ព្រឹង : ចាស ។

ដានី : កាលហ្នឹងឪពុកលោកយាយគាត់ឈ្មោះអី?

ព្រឹង : ឪពុកខ្ញុំឈ្មោះ ឆោម ។

ដានី : បាទ ។

ព្រឹង : ឈ្មោះ ឆោម ។

ដានី : ឈ្មោះ ឆោម ។

ព្រឹង : ចាស ។

ដានី : ម្ដាយ?

ព្រឹង : ម្ដាយឈ្មោះ ស៊ឹម ។

ដានី : ម្ដាយឈ្មោះ ស៊ឹម?

ព្រឹង : ចាស ។

ដានី : ចឹងឪពុកលោកយាយគាត់ជាអ្នកស្រុកនៅកំពង់ស្វាយហ្នឹង?

ព្រឹង : ចាស ។

ដានី : ចឹងម្ដាយលោកយាយឈ្មោះស៊ឹមនៅអើ?

ព្រឹង : ខាងខ្សាច់ពួន ។

ដានី : នៅខ្សាច់ពួនបាទ ចឹងឪពុកលោកយាយក្រុមគ្រួសារគាត់នៅតាំងស្វាយហ្នឹងយូរហើយ?

ព្រឹង : ម៉ែឪពុកខ្ញុំគាត់នៅយូរហើយ នៅតាំងពីប៉ុន្មានបើកាលហ្នឹងខ្ញុំនៅតូច ។

ដានី : ចឹងលោកយាយដាក់ឈ្មោះត្រកូលឯកព្រឹង?

ព្រឹង : ចាស ។

ដានី : ឯកហ្នឹងត្រូវជាយ៉ាងម៉េចលោកយាយ?

ព្រឹង : ឯកហ្នឹងជីតា ។

ដានី : ឯកហ្នឹងជីតា?

ព្រឹង : ចាស ។

ដានី : ចឹងជីតា ឈ្មោះឯក?

ព្រឹង : ចាស ។

ដានី ៖ ចុះយាយ?

ព្រីង ៖ យាយឈ្មោះ លាប់ ។

ដានី ៖ យាយឈ្មោះ លាប់?

ព្រីង ៖ ចាស ។

ដានី ៖ ចឹងតាឆោមកូនតា?

ព្រីង ៖ កូនតាឯក ។

ដានី ៖ កូនតាឯក?

ព្រីង ៖ ចាស ។

ដានី ៖ ចឹងតាឆោមមានបងប្អូនប៉ុន្មាននាក់ បងប្អូនឪពុកលោកយាយ?

ព្រីង ៖ មានតា ឈុំ តា ឆោម កែវ យាយ នឹម យាយ នុន តែប៉ុណ្ណឹង ។

ដានី ៖ តា ឈុំ តា ឆោម ។

ព្រីង ៖ ចាស ។

ដានី ៖ តា កែវ យាយនុំ?

ព្រីង ៖ យាយនឹម ។

ដានី ៖ យាយនឹមហើយនិងយាយនុន?

ព្រីង ចាស ។

ដានី ៖ យាយនុនជាឪពុក?

ព្រីង ៖ ម្ដាយ ។

ដានី ៖ ម្ដាយយាយ?

ព្រីង ៖ ម្ដាយតា “**អាន**” ម្ដាយតា “**យឿង**”ហ្នឹង ។

ដានី ៖ ម្ដាយតា អាន ម្ដាយតា យឿន?

ព្រីង ៖ តា “យឿង” ។

ដានី ៖ យឿងណែស?

ព្រីង ៖ ចាស ។ អ្នកជិតខាងនិយាយ“តា យឿងហៅ អាន” ។

ដានី ៖ តា យឿងហៅ អាន ។

ព្រីង ៖ ចាស ។

ដានី ៖ តា យឿងហៅអានហ្នឹង ម្ដាយគាត់ឈ្មោះយាយ នុន ចុះឪពុកគាត់?

ព្រីង ៖ ម្ដាយឈ្មោះយាយ នុន ឪពុកឈ្មោះ តា អោ ។

ដានី :	ឪពុកឈ្មោះ តា អោ?

ព្រីង :	ចាស ។

ដានី :	ចឹងឪពុកតា អោ ឈ្មោះអីទៅលោកយាយ?

ព្រីង :	ខ្ញុំអត់ស្គាល់ទេ ខ្ញុំនៅក្មេងៗ ។

ដានី :	អ! ចុះតាយឿងហៅតា អានហ្នឹងគាត់មានបងប្អូនបង្កើតប៉ុន្មាននាក់?

ព្រីង :	បងយ៉ុង បងគេ ។

ដានី :	ឈ្មោះអី?

ព្រីង :	យ៉ុង ។

ដានី :	បងយ៉ុងបាទ ។

ព្រីង :	យ៉ុង ហើយ យឿង ។

ដានី :	យ៉ុង ហើយ យឿង?

ព្រីង :	យឿងហើយ ណាន ។

ដានី :	យឿង ហើយណាន ។

ព្រីង :	ណានហើយ នៅ ។

ដានី :	នៅ បាទ ។

ព្រីង :	នៅហើយ វ៉ាត អាយ៉េង គេឈ្មោះយ៉េង «អ្នកជិតនិយាយត ចឹងមិនមែនឈ្មោះវ៉ាតទេ ចុះ? វ៉ាតហ្នឹងមិនដឹងទេ ទើបក្រោយទេ ។

ដានី :	ចាំមើល តា អាន បងគាត់ បងទី១ឈ្មោះ យ៉ុង?

ព្រីង :	ចាស ។

ដានី :	យ៉ុងប្រុសឬស្រី?

ព្រីង :	ប្រុស ។

ដានី :	ប្រុស សព្វថ្ងៃគាត់នៅណា?

ព្រីង :	ងាប់បាត់ហើយ ។

ដានី :	គាត់ស្លាប់ហើយ ស្លាប់នៅស្រុកយើងឬនៅណា?

ព្រីង :	ស្លាប់នៅត្រពាំងស្រង៉ែ ។

ដានី :	ស្លាប់នៅត្រពាំងស្រង៉ែ ទី២ឈ្មោះ យឿង យឿងហ្នឹងតា អានហ្នឹង?

ព្រីង :	ចាស ។

ដានី :	ហើយទី៣?

ព្រីង :	ទី៣ឈ្មោះ ណាន ។

ដានី :	ទី៣ឈ្មោះ នឹម?

ព្រីង :	ឈ្មោះ ណាន ។

ដានី :	ណាន ស្រី បាទ! ទី៤?

ព្រីង :	ទី៤ឈ្មោះ នៅ ។

ដានី :	នៅស្រីឬប្រុស?

ព្រីង :	ស្រី ។

ដានី :	ទី៥?

ព្រីង :	យ៉េង ។

ដានី :	យ៉េងស្រីប្រុស?

ព្រីង :	ប្រុស ។

ដានី :	ចឹងឈ្មោះ យឿងហៅ អានហ្នឹងលោកយាយអត់មានដឹងថាគាត់នៅណាទេ?

ព្រីង :	ខ្ញុំអត់ដឹងទេ ។

ដានី :	អត់ដឹងទេ?

ព្រីង :	ចាស!ខ្ញុំអត់ដឹង ។

ដានី :	ចុះឈ្មោះណាន?

ព្រីង :	ណានស្លាប់ ។

ដានី :	ណាន ស្លាប់ហើយ ចុះនៅ?

ព្រីង :	នៅក៏នៅដែរ តែមិនដឹងជាគេនៅណា ខ្ញុំអត់ដឹង ។

ដានី :	អត់ដឹងដែរ ។

ព្រីង :	ចាស!ខ្ញុំអត់ដឹងដែរ ។

ដានី :	ចុះឈ្មោះយ៉េង?

ព្រីង :	យ៉េងក៏នៅ តែដឹងគេនៅណា ខ្ញុំអត់ដឹងដែរ?

ដានី :	អ!អត់ដឹងដែរ ។

ព្រីង :	ចាស!ខ្ញុំអត់ដឹងដែរ ។

ដានី :	ចឹងយឿងហៅអានហ្នឹងប្រពន្ធគាត់ឈ្មោះអី?

ព្រីង :	អត់ស្គាល់ទេប្រពន្ធខ្ញុំអត់ស្គាល់ ។

ដានី :	អត់ដែលដឹងថាគាត់យកប្រពន្ធគាត់នៅណាអីណាទេ?

ព្រឹង ៈ	ប្រពន្ធយកកូនខ្មោចតា ឃិន យាយ រឹន តែមិនដឹងជាឈ្មោះអី បើខ្ញុំអត់ស្គាល់គេផង អត់ស្គាល់ ម្តាយមីងអា សេង មិនដឹងជាឈ្មោះស្អីផង ប្អូនយាយ...។

ដានី ៈ	ចឹងប្រពន្ធគាត់កូនរបស់តា ឃិន យាយ រឿន?

ព្រឹង ៈ	យាយ រឹន ។

ដានី ៈ	យាយរឹន?

ព្រឹង ៈ	ចាស ។

វណ្ណៈ ៈ	យាយរឹននៅភូមិហ្នឹងដែរ?

ព្រឹង ៈ	ស្លាប់អស់ហើយ ។

ដានី ៈ	នៅភូមិណាពួកគាត់?

ព្រឹង ៈ	នៅភូមិក្រាំងដូង ដឹងតាពូនដឹងក្រាំងដូងបើមិនច្បាស់ដែរ ផ្ទះយាយថាវនេះ ។ អ្នកជិតនិយាយ នៅក្រាំងដូងទេ ត្រឹមផ្ទះតា កាំងទៅកើតក្រាំងដូង ។

ដានី ៈ	នៅក្រាំងដូងហ្នឹង ក្រាំងដូងហ្នឹងក្នុង?

ព្រឹង ៈ	ឃុំពាមយើងដែរ ។

ដានី ៈ	ឃុំពាមយើងដែរ ស្រុកសាមគ្គីមានជ័យដែរ?

ព្រឹង ៈ	ចាស ។

ដានី ៈ	គាត់មានកូនចៅប៉ុន្មាននាក់ដែលលោកយាយ?

ព្រឹង ៈ	អ្នកណា?

ដានី ៈ	តា អាន?

ព្រឹង ៈ	ខ្ញុំអត់ដឹងទេ ។

ដានី ៈ	អត់ដឹងទេណាស់?

ព្រឹង ៈ	បើខ្ញុំទៅម្តងទៅរកកូននោះអត់មានកូនផង ។

ដានី ៈ	អត់មានកូនទេ?

ព្រឹង ៈ	អត់មានទេ "អ្នកជិតនិយាយមានប្រពន្ធក្រោយ" ព្រឹងនិយាយវិញ មានប្រពន្ធក្រោយណាប្រពន្ធតែមួយទេអី បើអត់សូវដឹងសាវដាគេដែរ ។

ដានី ៈ	អត់សូវដឹងដែរ?

ព្រឹង ៈ	ចាស! ព្រោះគេមានដែលនៅផ្ទះអីអត់សោះ ។

ដានី ៈ	ចឹងកាលពីក្មេងៗលោកយាយស្គាល់គាត់ច្បាស់ដែរ?

ព្រឹង ៈ	ស្គាល់ច្បាស់តើ បើខ្ញុំធំហើយ ។

ដានី ៖ ធំហើយ គាត់ជាមួយលោកយាយពីណាអាយុច្រើនជាង?

ព្រឹង ៖ គាត់បងខ្ញុំច្រើនណាស់ ។

ដានី ៖ បងច្រើនដែរ?

ព្រឹង ៖ គាត់បែប៨០សិបបាត់ទៅហើយ ៨០ហើយ អាយុគាត់នោះ ។

ដានី ៖ បាទ ។

ព្រឹង ៖ បើគាត់បួសភឹកហើយខ្ញុំទើបតែជិទង់ហ្នឹង ។

ដានី ៖ អរ!កាលគាត់បួសភឹកលោកយាយជំទង់ លោកយាយអាយុប៉ុន្មានកាលហ្នឹង?

ព្រឹង ៖ អាយុបែបបួនប្រាំដបអីប៉ុណ្ណឹង បួនដបអីប៉ុណ្ណឹងខ្ញុំនៅរៀនសាលាថ្នាក់ទី១-២ថ្នាក់ទី១២ ។

ដានី ៖ ឆ្នាំណាលោកយាយចាំទេ?

ព្រឹង ៖ ទេ ដឹងឆ្នាំប៉ុន្មានទេ អត់ចាំទេ រឿងឆ្នាំនោះ សើច...។

ដានី ៖ បាទ ។

ព្រឹង ៖ អត់ចាំទេ ។

ដានី ៖ អត់ចាំទេ?

ព្រឹង ៖ ចាស ។

ដានី ៖ តាំងពីជំនាន់រាស្ត្រនិយមតាំងពីជំនាន់សម្តេច?

ព្រឹង ៖ អត់ចាំទេរឿងឆ្នាំ ។

ដានី ៖ គាត់បួសនៅវត្តណា?

ព្រឹង ៖ បួសនៅវត្តតាំងខ្មៅ ។

ដានី ៖ គាត់បួសនៅវត្តតាំងខ្មៅ?

ព្រឹង ៖ ចាស ។

ដានី ៖ បួសនៅវត្តតាំងខ្មៅ កាលហ្នឹងគាត់ដាក់ឈ្មោះអី?

ព្រឹង ៖ ឈ្មោះយឿង ។

ដានី ៖ ឈ្មោះយឿង?

ព្រឹង ៖ ចាស ។

ដានី ៖ គាត់មានឈ្មោះអានទេ?

ព្រឹង ៖ អត់មានឈ្មោះអានផង អានហ្នឹងទើបពុក្រោយទេ គេហៅអានហ្នឹង ខ្ញុំអត់ដែលពុឈ្មោះចឹងផង អ្នកណាក៏ស្គាល់តែយឿងដែរ មិនដែលស្គាល់អានផង ។

ដានី ៖ ស្គាល់តែ តា យឿងៗ?

ព្រីង ៖ ចាស ។

ដានី ៖ គាត់បួសបានច្រើនដែរ?

ព្រីង ៖ គាត់បួសប្រហែល១០វស្សាដែលដឹងអី បួសយូរសឹងអីនោះ ស្អូវអស់ហើយកាលហ្នឹងនោះ ទំរាំសឹកនោះ ។

ដានី ៖ បាទ! ហើយគាត់បួសហ្នឹងបានធ្វើអីដែរ ដូចថាបានធ្វើសង្ឃរាជអីដែរអត់ទេ?

ព្រីង ៖ គាត់ត្រឹមគ្រូសូត្រ ។

ដានី ៖ គាត់ត្រឹមគ្រូសូត្រណែស?

ព្រីង ៖ ចាស ។

ដានី ៖ បួសនៅវត្តតាំងខ្មោចរហូតអត់មានទៅណាទេ?

ព្រីង ៖ អត់មានទៅវត្តណាទាំងអស់ គាត់នៅតែហ្នឹង ។

ដានី ៖ រហូតដល់ពេលណាបានគាត់សឹកលោកយាយដឹងទេ?

ព្រីង ៖ យូរដែលមិនដឹងកំណត់ថាឆ្នាំណាទេ ព្រោះខ្ញុំវាមិនចាំមិនដឹងជានិយាយថាម៉េច ។

ដានី ៖ តែដឹងថាគាត់សឹកមក គាត់មកនៅក្នុងភូមិយើងអីយ៉ាងម៉េចដែរ?

ព្រីង ៖ "អ្នកនៅជិតនយាយសឹកមកទៅបាត់" ព្រីង និយាយវិញ អត់ទេ សឹកមកនៅផ្ទះបានមួយឆ្នាំដែលបានបាត់ខ្លួន ។

ដានី ៖ បាត់ទៅណាទៅ?

ព្រីង ៖ បើមិនដែលឃើញដឹងគេទៅណាមកណើ ទៅណាកាលនោះបើខ្ញុំមិនដឹងគេផង ។

ដានី ៖ កាលគាត់សឹកលោកយាយអត់មានចាំថាគាត់សឹកពេលណាទេ?

ព្រីង ៖ អត់ចាំទេខ្ញុំ ។

ដានី ៖ ពេលហ្នឹងសឹកមកហ្នឹងពេលមានសង្គ្រាម នៅក្នុងស្រុកភូមិយើងមានសង្គ្រាមមានអីហើយឬអត់ទេ?

ព្រីង ៖ អត់ទេ អត់ទាន់មានសង្គ្រាមផង ។

ដានី ៖ អត់ទាន់មានសង្គ្រាមទេ?

ព្រីង ៖ ចាស ។

ដានី ៖ គាត់មានប្រពន្ធនៅកាលពេលហ្នឹង?

ព្រីង ៖ អត់មានប្រពន្ធទេ គាត់កំលោះចាស់ ។

ដានី ៖ គាត់កំលោះចាស់?

ព្រីង ៖ ចាស!អត់មានប្រពន្ធទេ ។

ដានី ៖ អឺ ។

ព្រឹង ៖ បើមានប្រពន្ធហ្នឹងទើបគេថាមានប្រពន្ធឥឡូវទេ ក្រោយមកឥឡូវទេ កាលនោះអត់មានប្រពន្ធទេ កាលហ្នឹងគេរវល់តែចំអន់ជាមួយបងឆន តែគាត់អត់ស្រឡាញ់ផង ។

ដានី ៖ គាត់អត់ស្រឡាញ់ទេ?

ដារ៉ា ៖ ចុះលោកយាយចេះដូចថាលោកយាយអត់ចាំឆ្នាំហ្នឹង លោកតាយឿងហ្នឹងនៅពេលដែលគាត់សឹកមកវិញ លោកយាយអាយុប៉ុន្មានហើយ?

ព្រឹង ៖ អឺស!វាមិនចាំអាយុខ្លួនឯងហ្នឹងទៀតហ្នឹងណាស់ មិនដឹងជាអាយុប៉ុន្មានហើយបើខ្ញុំអត់ចាំដែលហ្នឹង ដឹងនិយាយថាម៉េច ។

ដារ៉ា ៖ ដូចថាលោកយាយនិយាយពីខាងដើមមិញហ្នឹងលោកយាយ លោកយាយថា?

ព្រឹង ៖ ខ្ញុំការហើយនៅទេ ខ្ញុំការហើយនៅបានមួយឆ្នាំបានលែងឃើញមិនដឹងជាទៅណា ។

ដារ៉ា ៖ ចឹងលោកយាយបានរៀបការហើយបានមួយឆ្នាំហើយបានបាត់ឈ្មោះយឿងហ្នឹងពីភូមិហ្នឹងទៅ?

ព្រឹង ៖ ចាស ។

ដារ៉ា ៖ បាទ! ពេលដែលបាត់ហ្នឹងអត់មានលេចឮដំណឹងថាទៅណាមកណាទេ លោកយាយ?

ព្រឹង ៖ អត់ កាលហ្នឹងមនុស្សចេះតែរត់អស់រលីងពីភូមិ ដឹងណាទៅណា ណាទៅណីកាលហ្នឹង ។

ដារ៉ា ៖ អឺ! ។

ព្រឹង ៖ ប្រុសៗអត់មានពីណានៅផង ចេះតែទៅអស់ទៅ ។

ដារ៉ា ៖ ចឹងនៅពេលលោកយាយដឹងថាឈ្មោះ យឿងនេះដូរមកឈ្មោះអានវិញ នៅពេលណាដែលលោកយាយដឹងចឹង?

ព្រឹង ៖ ខ្ញុំទើបតែរំដោះបានហើយ ខ្ញុំទៅលេងបងប្អូនឮគេនិយាយនៅហ្នឹង ។

ដារ៉ា ៖ ទៅលេងបងប្អូននៅណា?

ព្រឹង ៖ បងប្អូននៅខ្សាច់ពូន ។

ដារ៉ា ៖ ខ្សាច់ពូន?

ព្រឹង ៖ ចាស់ៗគាត់និយាយ"អ្នកជិតនិយាយ គាត់ថាដល់គេហៅឈ្មោះហ្នឹងគាត់អត់ស្គាល់ផងគាត់អត់ដឹងគេដូរស់ឈ្មោះផង" ព្រឹងនិយាយវិញ ខ្ញុំអត់ស្គាល់ខ្ញុំស្គាល់ឈ្មោះតែយឿង ។

ដារ៉ា ៖ បាទ ។

ព្រឹង ៖ ត្រង់អានហ្នឹងខ្ញុំអត់ស្គាល់ មិនដែលឮមានពីណាហៅផងស្រុកហ្នឹងអត់ អត់មាន ។

ដារ៉ា ៖ អឺ! ។

ព្រីង :    អត់មាន ។

ដារ៉ា :    ដល់ចឹងទៅលោកយាយធ្វើដំណើរទៅរកកូននៅណា នៅអន្លង់វែងចឹង?

ព្រីង :    ចាស ។

ដារ៉ា :    ទៅៗក៏បានជួបឈ្មោះយឿងហ្វីង?

ព្រីង :    ចាស ។

ដារ៉ា :    ហើយនៅអន្លង់វែងជួបឈ្មោះយឿងហ្វីង ដូរជាឈ្មោះអានរហូតចឹង?

ព្រីង :    គេហៅនៅហ្វីង គេ ហៅតែតា អានៗ ហើយខ្ញុំធ្លាប់តែយឿង ដល់តា អានហ្វីងវាមិនដែលឮខ្ញុំនិយាយត្រង់ ។

ដារ៉ា :    គាត់មានរូបរាងយ៉ាងម៉េចអីយ៉ាងម៉េច?

ព្រីង :    រូបរាងគាត់តូចល្អិតដែរ ។

ដារ៉ា :    តូចល្អិតហើយសម្បុរសឬខ្មៅ?

ព្រីង :    សម្បុរសណែកបាយ តូចល្អិត រកអ្នកណាប្រដូចមិនបាន រាងល្អិតដូចក្មួយនេះតែគ្រាន់តែខ្មៅទេ ។

ដារ៉ា :    អឺ ។

ព្រីង :    រាងល្អិតមែនទែនទៅណាស់ ។

ដានី :    ចុះសក់គាត់យ៉ាងម៉េចដែរ?

ព្រីង :    សក់សម៉ាវអស់ហើយ ។

ដានី :    អត់ទេ គាត់សក់ស្កួតឬសក់រួញ?

ព្រីង :    សក់រួញដែរ ។

ដានី :    សក់រួចដែរ?

ព្រីង :    សក់គាត់ ។

ដារ៉ា :    ចឹងមាឌល្អិតតូចទេ ចឹង?

ព្រីង :    ចាស ។

ដារ៉ា :    ហើយខ្មៅ?

ព្រីង :    មិនខ្មៅទេ សម្បុរសណ្តែកបាយ ។

ដារ៉ា :    សម្បុរសណ្តែកបាយ! ចុះសម្តីគាត់យ៉ាងម៉េចដែរ?

ព្រីង :    សម្តីរៀងដូចស្រី សម្តីស្រី ។

ដានី :    សម្លេងស្រី?

ព្រឹង : ចាស ។

ដានី : គាត់កាចប្រស្ងួតមនុស្សគាត់?

ព្រឹង : មនុស្សដែលនៅហ្នឹងគាត់អត់មានកាចផង បងប្អូនអីគាត់អត់ចេះទាស់ទែងចេះចុះអីគ្នាអីផង នៅផ្ទះស្ងួតសឹងអី ។

វណ្ណៈ : ចឹងគាត់មានដែលមកលែងស្រុកកំណើតអីម្តងដែលទេ?

ព្រឹង : អត់ដែលទេ ។

វណ្ណៈ : ចឹងមិនដែលទេ?

ព្រឹង : ចាស!មិនដែលទេ ។

វណ្ណៈ : ចឹងកាលដែលអ៊ឹអញ្ជើញទៅអន្លង់វែងហ្នឹង តើអ៊ឹអញ្ជើញទៅប្រហែលគេចរចារហើយប្អុក៏បែករំដោះហើយឆ្នាំ៧៩ប៉ុន្មានឆ្នាំបានអ៊ឹអញ្ជើញទៅរកកូនប្អុក៏យូរដែលបានអញ្ជើញទៅ?

ព្រឹង: ទៅមិនដឹងជាឆ្នាំប៉ុន្មានទៅតាមគេតាមឯង «អ្នកជិតនិយាយ បែបគេចរចារហើយបានទៅ» ព្រឹង និយាយវិញ មិនដឹងជាម៉េចទេកាលហ្នឹងភ្លេចបាត់ហើយ ព្រោះយូរណាស់ហើយ តាំងពីរំដោះបានមកហើយ បានទៅគេទៅគគោកគដីទៅជាមួយគេទៅ ទៅរកវាមិនឃើញទៀតបានតែទឹកភ្នែក ។

ដារ៉ា : ចឹងលោកយាយជួបកូនលោកយាយម្នាក់ក្រោយនេះ ជួបតាមរយៈយ៉ាងម៉េច?

ព្រឹង : ហ្នឹងវាមកប្តីវាជូនមក ។

ដារ៉ា : ជូនមកឯងទេ?

ព្រឹង : ជូនមកដល់ផ្ទះបណ្តោយ ខ្ញុំទៅរកហ្នឹងខ្ញុំរកអត់ឃើញ គេថា មីហ្នឹងគេយកលក់ឲ្យថៃបាត់ ហើយគេប្រាប់ខ្ញុំចឹង ហើយមីមួយទៀតងាប់បាត់ហើយ ងាប់នៅជើងភ្នំអីណាទេ ហើយខ្ញុំទៅរកណាខ្ញុំត្រឡប់មកវិញទៅ ។

ដានី : ពីណាជាអ្នកប្រាប់លោកយាយថា កូនគេយកលក់ឲ្យថៃហើយម្នាក់ទៀតស្លាប់ហើយ?

ព្រឹង : តា«**អានហ្នឹង**» ។

ដានី : តា អានប្រាប់ចឹង?

ព្រឹង : ហើយខ្ញុំមិនដឹងជាធ្វើម៉េច គេប្រាប់ចឹងហើយខ្ញុំមកវិញមក ដល់មកបានប៉ុន្មានឆ្នាំទេបានកូនមករកម៉ែវិញ ជួបគ្នាទៅ ។

ដានី : ឆ្នាំណា?

ព្រឹង : កូនលោកយាយនិយាយ ខ្ញុំមកកាលបោះឆ្នោតហើយហ្នឹង ៩៣-៩៤ហ្នឹង ។

ដានី : ៩៣-៩៤ហ្នឹង?

ព្រឹង :	ចាស ។

ដានី :	ចឹងលោកយាយទៅរកបានប៉ុន្មានឆ្នាំបានកូនលោកយាយហ្នឹងមក?

ព្រឹង :	ចូលប្រហែល១០ឆ្នាំជាងហើយបើយូរដែរ  តាំងពី៨០នោះ  តែទៅមិនដឹងជា៨០ប៉ុន្មាន ខ្ញុំទៅហ្នឹង ខ្ញុំភ្លេចទៅដែរ ។ អ្នកជិតនិយាយ ទៅបាន៣ឆ្នាំ៤ឆ្នាំបានមក ។

ដានី :	លោកយាយនិងតា អានហ្នឹងត្រូវជាជីដូនមួយ?

ព្រឹង :	ជីដូនមួយ ។

ដារ៉ា :	ចឹងនៅក្នុងផ្ទះលោកយាយរាល់ថ្ងៃមាននៅសល់រូបថតតា អានទេ?

ព្រឹង :	អត់ទេ អត់មានទេ ។

ដារ៉ា :	ជីដូនមួយថតជាមួយគ្នា?

ព្រឹង :	ជីដូនមួយកាលហ្នឹងមានថតណា សូម្បីតែការក៏អត់មានថតដែរ ។

ដារ៉ា :	អរ!សូម្បីតែការប្តីប្រពន្ធហ្នឹងអត់មានរូបថតដែរ?

ព្រឹង :	អត់មានថតទេ កាលហ្នឹងសូម្បីតែរាំវង់ស្គរអ្នកភ្លេងហ្នឹង ។

ដារ៉ា :	ស្គរដីយើងហ្នឹង?

ព្រឹង :	ចាស!ចេះតែវ៉ៃប៉ាក់បឹត១ទៅ ចេះតែឡុកទៅ ។

ដារ៉ា :	មានហូបការមានគុមានអីចឹងទេ?

ព្រឹង :	អត់មានទេ កន្ទាលគ្នោតក្រាលចឹងទៅ អត់មានដូចគេឥឡូវទេ ។

ដារ៉ា :	អត់មានរូបថតលោកយាយណើស ឥឡូវគេមានរូបថតអីណាស់?

ព្រឹង :	គេមានរូបថត ។

ដារ៉ា :	អត់សោះកាលជំនាន់ហ្នឹង?

ព្រឹង :	អត់ទេ ។

ដានី :	ចឹងខ្ញុំចង់សួរប្រវត្តិលោកយាយតិចចឹង  លោកយាយចឹង  លោកយាយការហើយមកនៅ ស្រុកភូមិយើងហ្នឹង លោកយាយប្រកបមុខរបរធ្វើអីទៅ?

ព្រឹង :	ខ្ញុំធ្វើស្រែ ។

ដានី :	ធ្វើស្រែធ្វើចំការ?

ព្រឹង :	ចាស ។

ដានី :	ធ្វើរហូតដល់ពេលណា?

ព្រឹង :	ធ្វើរហូតដល់ពេលគេរួមជម្រុករួមអីហ្នឹងនៅតែធ្វើតែស្រែហ្នឹង តែរហូត ។

ដានី :	ដល់ពេលរួមហ្នឹងយ៉ាងម៉េចទៅនៅស្រុកភូមិយើង នៅបាយរួម៧៥មក?

ព្រីង ៖	ពេលបាយរួមហ្នឹងមុនដំបូងបាយ រួចពីបាយទៅបបរពាវ១ អង្ករសម្រួបដាំបាយរួចពីហ្នឹង អាគាត់អាគាយរហូតទៅ ។

ដានី ៖	កាលហ្នឹងលោកយាយមានកូនប៉ុន្មាននាក់ហើយ?

ព្រីង ៖	ខ្ញុំកូនមើល ១-២បួននាក់ហើយ ។

ដានី ៖	កូនបួនហើយ?

ព្រីង ៖	ចាស ។

ដានី ៖	កាលហ្នឹងមានកូនបួននាក់ កាលហ្នឹងកូនលោកយាយនៅជុំជាមួយលោកយាយឬមួយនៅបែកគ្នា?

ព្រីង ៖	កូនខ្ញុំបែកពីរ នៅពីរ ។

ដានី ៖	កាលហ្នឹងបែកពីរឈ្មោះអីខ្លះ?

ព្រីង ៖	បែកមីបងស្រីហ្នឹងឈ្មោះ បូរី ហើយ បូ រ៉ុមពីរហ្នឹង ។

ដានី ៖	កាលហ្នឹងបែកទៅណាទៅ?

ព្រីង ៖	បែកវាទៅតាមគេហ្នឹង នៅកន្លែងកុមារហ្នឹង ។

ដានី ៖	ទៅតាមពីណាគេ?

ព្រីង ៖	មីនោះទៅតាមវ៉ាត ទៅតា អាយ៉េង គេយកទៅខ្ញុំថាមិនឲ្យទៅវានៅតែទៅ ។

ដានី ៖	តាមពីណា តាមយ៉េងប្អូនតា អានហ្នឹង?

ព្រីង ៖	ចាស ។

ដានី ៖	យ៉េងហ្នឹងកាលហ្នឹងគាត់ធ្វើអី?

ព្រីង ៖	ទេ អត់ដឹងគេ សួរខ្ញុំចឹងខ្ញុំអត់ដឹងទេ "កូនគាត់និយាយ គាត់ធ្វើការដែល តែដឹងធ្វើការខាងអី" ។

ដានី ៖	គាត់នៅណា គាត់នៅភ្នំពេញ?

ព្រីង ៖	គាត់នៅភ្នំពេញ គាត់នៅបឹងសំយ៉ាបហ្នឹង ។

ដានី ៖	នៅបឹងសំយ៉ាប?

ព្រីង ៖	កូនគាត់និយាយ "ចាស" ។

ដានី ៖	ចឹងឈ្មោះយ៉េងហ្នឹងយកកូនលោកយាយទៅ?

ព្រីង ៖	ចាស ។

ដានី ៖	យកបូ រ៉ុម ចុះ បូរី?

ព្រីង ៖	បូរី នៅជាអ្នកយកទៅ ។

ដានី ៖ នៅហ្នឹងគាត់ធ្វើអីដែលបានជាយកកូនលោកយាយទៅ?

ព្រឹង ៖ ដឹងអី ថាសុំមួយបងប្អូនយកទៅឲ្យរៀន ពុថាគេយកទៅឲ្យរៀន កាលនៅសហករណ៍វាវេទនាពេក វាទៅតាមគេទៅ ឃាត់វាក៏ឃាត់មិនបាន ។

ដានី ៖ ឆ្នាំណាលោកយាយ?

ព្រឹង ៖ ឆ្នាំប៉ុន្មានមិនដឹង ៧០មិនដឹង៧៣មិនដឹងទេ ភ្លេចអស់ហើយ ។

ដានី ៖ ៧៥បានបែកភ្នំពេញ ឆ្នាំ៧៥បានបាយរួម បានបែកភ្នំពេញណាស់?

ព្រឹង ៖ ចឹង៧៥ហើយកូនហ្នឹងទៅ ។

ដានី ៖ ចឹងទៅតាំងពីបែកភ្លាមៗម៉េះ?

ព្រឹង ៖ ៧៥ហើយកូនហ្នឹងទៅ ៧៥-៧៦ប៉ុណ្ណឹង ។

ដានី ៖ ចឹងលោកយាយអត់មានដឹងកូនលោកយាយទៅជាមួយឈ្មោះនៅហ្នឹង ទៅត្រង់ណាទៅធ្វើអីទេ?

ព្រឹង ៖ កាលហ្នឹងគេនៅអន្លង់វែងហ្នឹងបានជាខ្ញុំទៅរកកូនហ្នឹង?

ដានី ៖ អត់ទេ កាលពីសម័យ?

ព្រឹង ៖ កូននិយាយថា «ម៉ែមិនដឹងទេ គាត់ដឹងថានៅភ្នំពេញមែនតែមិនដឹងជាកន្លែងណា» ព្រឹងនិយាយវិញ តែកាលហ្នឹងដឹងថានៅភ្នំពេញគេយកទៅឲ្យរៀន ។

ដានី ៖ គេឲ្យរៀន?

ព្រឹង ៖ ចាស ។

ដានី ៖ ប៉ុន្តែអត់មានដឹងថារៀននៅណា អ្នកដែលយកទៅត្រូវជាជីដូនមួយលោកយាយហ្នឹងអត់មានដឹងថាគេនៅណាដែរ?

ព្រឹង ៖ អត់ដឹងទេ ។

ដានី ៖ ចុះកូនលោកយាយទៅធ្វើអីទៅ?

ព្រឹង ៖ វាតូចៗ តូចជាងមីនេះទៅទៀត ថាយកទៅឲ្យរៀន ។

ដានី ៖ កាលហ្នឹងអាយុប៉ុន្មានឆ្នាំ កាលហ្នឹង?

ព្រឹង ៖ កាលហ្នឹងអាយុបែប៧ឆ្នាំហើយកូនហ្នឹង ។

ដានី ៖ កូនប្រុ រឺហ្នឹង?

ព្រឹង ៖ ចាស!តូចហ្នឹងមានធំណា ។

ដានី ៖ តូចហ្នឹង?

ព្រឹង ៖ តូចហ្នឹងអាយុ៧ឆ្នាំ បើមីនេះទៅក្រោយបានអាយុ៩ឆ្នាំ ។

ដានី ៖ ៩ឆ្នាំទៅឆ្នាំណា?

ព្រីង ៖ បែប៧៦មិនដឹង៧៧មិនដឹង កាលហ្នឹងមីហ្នឹងទៅ ។

ដានី ៖ កាលហ្នឹងទៅជាមួយពូវ៉ាត?

ព្រីង ៖ កូនលោកយាយនិយាយ“ចាស” ។

ដានី ៖ ចឹងវ៉ាតហ្នឹងឈ្មោះយ៉េងទេ តែគាត់ដូរឈ្មោះវ៉ាត?

ព្រីង ៖ កូនលោកយាយនិយាយ“ចាស” ។

ដានី ៖ ទៅនៅជាមួយគាត់តែម្ដង?

ព្រីង ៖ កូនលោកយាយនិយាយ“ចាស” គាត់ឲ្យនៅផ្ទះមួយតែឯង គាត់នៅផ្សេង ។

ដានី ៖ ផ្ទះគាត់នៅណា?

ព្រីង ៖ កូនលោកយាយនិយាយ“ចាស” ខ្ញុំមិនដឹងជានៅណាទេ.... ។

ដានី ៖ ចឹងពូយ៉េងប្រពន្ធគាត់ឈ្មោះអី វ៉ាតហ្នឹង?

ព្រីង ៖ កូនលោកយាយនិយាយ ឈ្មោះ ជឿន ប្រពន្ធដើម ។

ដានី ៖ ប្រពន្ធដើមឈ្មោះជឿន?

ព្រីង ៖ កូនលោកយាយនិយាយ“ចាស” ។

ដានី ៖ ប្រពន្ធក្រោយ?

ព្រីង ៖ កូនលោកយាយនិយាយអត់ដឹង ។

ដានី ៖ សព្វថ្ងៃគាត់នៅណាចឹង?

ព្រីង ៖ កូនលោកយាយនិយាយ អត់ដឹង ។

ដានី ៖ អត់ដឹងទេ?

ព្រីង ៖ កូនលោកយាយនិយាយ“ចាស” ។

ដានី ៖ ចឹងលោកយាយដែលថាកូនពីរនាក់ដែលទៅភ្នំពេញហ្នឹង ដូចថាតាំងពីទៅហ្នឹងមានដែលមកលេងផ្ទះអីដែរ?

ព្រីង ៖ អត់ដែលមករលីង ។

ដានី ៖ អត់ដែលមក?

ព្រីង ៖ រួចដល់ពេលគេបែកភ្នំពេញហ្នឹង ខ្ញុំហ្នឹងកាត់រកកូនខ្វែងខ្វាត់ក៏រកមិនឃើញ ។

ដានី ៖ ចុះកាលពីជំនាន់ហ្នឹងលោកយាយធ្វើការងារអីទៅ?

ព្រីង ៖ មានធ្វើការងារអី មានតែគេឲ្យរោយស្រូវ ។

ដានី ៖ រោយស្រូវ?

ព្រឹង : ចាស ។

ដានី : រោយស្រូវនៅណា?

ព្រឹង : រោយស្រូវនៅកន្លែងឃ្លាំងគេហ្នឹង ។

ដានី : ឃ្លាំងនៅណាទៅ?

ព្រឹង : ឃ្លាំងនៅកន្លែងត្រង់ផ្ទះតា ជាតរាល់ថ្ងៃនេះ ក្នុងសហករណ៍ ។

ដានី : ក្នុងភូម?

ព្រឹង : ក្នុងភូមចន្ទារៀលហ្នឹង ។

ដានី : ភូមិចន្ទារៀល?

ព្រឹង : ចាស ។

ដានី : បាទ! ចុះលោកតា?

ព្រឹង : ប្ដីខ្ញុំគេទៅតាមការរដ្ឋាន ដឹងគេទៅធ្វើស្អីខ្ញុំអត់ដឹងដែរ បិតតែថាប្ដីប្រពន្ធដឹងគេទៅខាងស្អី ។

ដានី : គាត់ធ្វើមានតួនាទីអីដែរ?

ព្រឹង : អត់មានតួនាទីអីទេ ប្ដីខ្ញុំមានតែកងចល័តចុះឡើង ។

ដានី : បាទ ។

ព្រឹង : មិនដឹងជាគេធ្វើស្អី ។

ដានី : ចឹងពេលល្ងាចមកនៅជុំគ្នាវិញ?

ព្រឹង : អត់ទេ គេនៅតែហ្នឹងទេ ខ្ញុំនៅផ្ទះហ្នឹង ។

ដានី : ចឹងប្ដីនៅណា នៅហ្នឹង?

ព្រឹង : ដឹងកន្លែងគេណា គាត់ថានៅទន្លេនៅអី អីណុងជាមួយគេកងចល័ត កងចល័តមានធ្វើស្អី គាត់ ។

ដានី : បាទ ។

ព្រឹង : មានធ្វើការងារអីផង ។

ដានី : ចឹងឈ្មោះយ៉េង ឈ្មោះ នៅ ដែលថាយកកូនលោកយាយទៅហ្នឹងគាត់មានធ្លាប់មកលេង ស្រុកភូមិដែលអត់ កាលជំនាន់ណុង?

ព្រឹង : កាលឆ្នាំមុនហ្នឹងមក ។

ដានី : ជំនាន់ប៉ុល ពត កាលជំនាន់បីឆ្នាំ?

ព្រឹង : អត់ទេ អត់ដែលជួបទេ អត់តែម្ដង ។

ដានី : អត់តែម្ដង ចឹងឆ្នាំណាបានគាត់មកលេងស្រុក?

ព្រឹង ៈ ឆ្នាំប៉ុន្មានដែលមកហ្នឹង មីរ៉ែនពីថ្ងៃណាដែលមកហ្នឹងនោះណាស់ វាអត់ចាំទេ ។

ដានី ៈ អត់ចាំទេណាស់?

ព្រឹង ៈ កូនលោកយាយនិយាយ កាលដែលខ្ញុំមកហ្នឹងដំបូងជាមួយប្តីខ្ញុំហ្នឹង គាត់មកហ្នឹងឯង ។

ដានី ៈ អឺ ។

ព្រឹង ៈ កាលជួបមិនដឹងពីថ្ងៃណាឆ្នាំប៉ុន្មាន វាភ្លេចឆ្នាំហើយនេះ ឆ្នាំប៉ុន្មាន កាលនៅវាមកហ្នឹងនោះ ឆ្នាំប៉ុន្មាន ភ្លេចឆ្នាំ "អ្នកជិតនិយាយ" មកប្អូនឆ្នាំហើយដឹង ។

ដានី ៈ ពីណាមកហ្នឹង?

ព្រឹង ៈ កូននិយាយ"មកតែម្តងទេមីង" ព្រឹងនិយាយវិញ មកម្តងកាលហ្នឹងមកធ្វើបុណ្យផ្ទះក្មួយគេនោះ ។

ដានី ៈ ផ្ទះពូសំ បូរហ្នឹង?

ព្រឹង ៈ មិនមែនទេផ្ទះក្មួយគេនៅត្បូងនោះ ឈ្មោះ ហាក់ ។

ដានី ៈ ឈ្មោះអីគេ?

ព្រឹង ៈ ឈ្មោះ ហាក់ ស៊ីម ។

ដានី ៈ ឈ្មោះ ហាក់ ស៊ីម ហ្នឹងក្មួយគាត់?

ព្រឹង ៈ ចាស!ក្មួយបង្កើត ។

ដានី ៈ ក្មួយបង្កើតក្មួយរបស់ពីណា?

ព្រឹង ៈ ក្មួយឈ្មោះនៅហ្នឹង ។

ដានី ៈ ក្មួយតាអានហ្នឹងដែរ?

ព្រឹង ៈ ចាស ។

ដានី ៈ ឈ្មោះ ស៊ីម?

ព្រឹង ៈ ឈ្មោះ ស៊ីម ប្តីឈ្មោះ ហាក់ ប្រពន្ធឈ្មោះ ស៊ីម គេមកធ្វើបុណ្យអីណុង ហើយគេមកអើតមួយភ្លេត គេមកហ្នឹងមួយភ្លេត តែវាភ្លេចឆ្នាំមិនដឹងជាឆ្នាំប៉ុន្មាន ។

ដានី ៈ ឈ្មោះ ហាក់និងឈ្មោះស៊ីមក្មួយបស់?

ព្រឹង ៈ ក្មួយរបស់អាន ។

ដានី ៈ ហាស់?

ព្រឹង ៈ ក្មួយ ។

ដានី ៈ ពីណាជាក្មួយពីរនាក់ហ្នឹង?

ព្រឹង ៈ ក្មួយបង្កើតស៊ីម ។

ដានី ៖ ស៊ីមហ្នឹងក្ដួយបង្កើត?

ព្រីង ៖ ហាក់ហ្នឹងសាច់ថ្លៃទេ ។

ដានី ៖ គាត់នៅភូមិអី?

ព្រីង ៖ នៅភូមិរលាំងថ្មើង ។

ដានី ៖ នៅភូមិរលាំងថ្មើង?

ព្រីង ៖ ចាស ។

ដានី ៖ ឃុំអីហ្នឹង?

ព្រីង ៖ អ្នកជិតនិយាយ ឃុំប្រាំបីមុំ ស្រុកថ្ពង ។

ដានី ៖ គាត់ធ្លាប់មកឈ្មោះ នៅហ្នឹង?

ព្រីង ៖ គាត់ធ្លាប់មកចូលមកលេង ខ្វាចខ្មោចស៊ីអត់ហ៊ានទៅហួសបងប្អូនចេះ ។

ដានី ៖ សើច... គាត់ថាចឹង?

ព្រីង ៖ ចាស ។

ដានី ៖ ចឹងឈ្មោះយើងគាត់ធ្លាប់មកទេ?

ព្រីង ៖ អត់ទេ ។

ដានី ៖ យើងអត់មក មកតែទៅ នៅគាត់នៅណាគាត់មានប្រាប់ទេ?

ព្រីង ៖ អ្នកជិតនិយាយ គាត់ថាគាត់នៅនោះនៅអន្លង់វែង ។

ដានី ៖ នៅកំរៀង?

ព្រីង ៖ បើខ្ញុំដឹងពីដើមថានៅអន្លង់វែង កាលខ្ញុំទៅរកកូនខ្ញុំ គេនៅអន្លង់វែង តែឥឡូវដឹងគេនៅណា បើវាមិនដឹង ។

ដានី ៖ អរ!ចឹង បាទ! គាត់មកតែម្ដងហ្នឹង?

ព្រីង ៖ មកតែម្ដងហ្នឹង ។

ដានី ៖ លោកយាយអត់មានទៅលេងគាត់ទៀតឥឡូវ?

ព្រីង ៖ អត់ទេ ខ្ញុំមិនដែលទៅទេ ។

ដានី ៖ ចុះដូចថាបងប្អូនដែរ ជីដូនមួយ?

ព្រីង ៖ បងប្អូនហ្នឹងខ្ញុំអត់មានស្អីទៅ ទៅស្មានអស់គិចណាស់ទៅរកអីបានខ្ញុំចំណាស់នេះទៅហើយ ។

ដានី ៖ ចឹងកាលលោកយាយទៅលេងគា អាន កាលឆ្នាំ៨០ជាងគាត់មានរាក់ទាក់អីជាមួយលោកយាយដែរ?

ព្រីង ៖ ខ្ញុំអត់មានទៅលេងទេ ខ្ញុំទៅរកកូនខ្ញុំតែម្ដង ។

ដានី ៖ បាទ! ទៅលេងទៅរកកូនហ្នឹងគាត់យ៉ាងម៉េចដែរ គាត់រាក់ទាក់ជួយរកកូនលោកយាយដែរ ឬយ៉ាងម៉េច?

ព្រីង ៖ អត់ទេ ខ្ញុំទៅ ខ្ញុំឃើញខ្ញុំសួរថាកូនខ្ញុំនៅណា? អញអត់ដឹងទេ អញឮគេថាងាប់ៗ សួរអញចឹងអញអត់ដឹងទេ ដល់ថាមិនដឹងចឹងឲ្យខ្ញុំធ្វើម៉េច ។«អ្នកជិតនិយាយថា មីងាប់ហើយ មីប្អូនគេយកទៅលក់ឲ្យថៃទៅហើយ» ។

ដានី ៖ ចុះម៉េចដឹងថាគេយកទៅលក់ឲ្យថៃអីចឹង ម៉េចគាត់មិនជួយផងក្រែងគាត់ត្រូវជាបងជាប់សាច់ញាតិដែរ?

ព្រីង ៖ បងប្អូនសាច់ញាតិមែន តែគេមិនគិតគូរយើង ។

ដានី ៖ គេអត់គិតគូរទេ?

ព្រីង ៖ បើគេគិតគូរយើងឲ្យយើងនៅរស់បាត់ហើយ មានលក់អីណាមីនេះមកក្រឡឹម អាងាប់នោះមិនដឹងជាងាប់មែនឬម៉េច ។

ដានី ៖ ចឹងបានន័យថាគាត់អត់មានគិតគូរអីផង?

ព្រីង ៖ អត់ ។

ដានី ៖ លោកយាយខឹងគាត់ដែរ?

ព្រីង ៖ ខឹងដែលណាស់ ខ្ញុំកូនណាស់ ស្រឡាញ់ «អ្នកជិតនិយាយថា គាត់និយាយយកកូនអញមកកើតដល់បាត់សួរអត់ដឹង» ចុះបើរត់បែកគ្នាអស់ហើយណាដឹង ។

ដានី ៖ ចុះអ្នកដែលយកទៅឈ្មោះ យ៉េង ឈ្មោះនៅអីហ្នឹង លោកយាយអត់ដែលទៅជួបគាត់ទេកាលហ្នឹង?

ព្រីង ៖ កាលហ្នឹងទៅជួបគេនៅហ្នឹងមូលគ្នាបងប្អូនគេហ្នឹង ។

ដានី ៖ ជួបគេអត់ថាអីដែរ?

ព្រីង ៖ គេថាងាប់បាត់ហើយ ។

ដានី ៖ គាត់ថាចឹង?

ព្រីង ៖ ចាស!នៅនេះរកហោទាយវាអស់ចិត្តហើយ ។

ដានី ៖ ចឹងលោកយាយ ក្នុងជំនាន់ហ្នឹងលោកយាយបាត់កូនអស់ប៉ុន្មាននាក់?

ព្រីង ៖ បាត់កូនអស់ពីរនាក់ ។

ដានី ៖ អស់ពីរនាក់ ឈ្មោះ បូ រីមួយហើយឈ្មោះណាទៀត?

ព្រីង ៖ មីនេះមកហើយ ។

ដានី ៖ មកវិញហើយចឹងបាត់តែមួយទេ?

ព្រឹង ៖ បាត់តែមួយ ។

ដានី ៖ ចឹងលោកយាយសព្វថ្ងៃហ្នឹងនៅភូមិអីគេទៅ លោកយាយ?

ព្រឹង ៖ ភូមិចន្ទារៀល ។

ដានី ៖ ឃុំអីដែរ?

ព្រឹង ៖ ឃុំពាម ។

ដានី ៖ ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង?

ព្រឹង ៖ ចាស ។

ដានី ៖ បាទ! ហើយលោកយាយប្រកបមុខរបររកស៊ីអីដែរ?

ព្រឹង ៖ ធ្វើស្រែ ខ្ញុំលែងធ្វើអីកើតហើយឥឡូវ ធ្វើបន្តិចបន្តួចតែកូន ។

ដានី ៖ ធ្វើស្រែ ចឹងខ្ញុំអរគុណលោកយាយច្រើន ។

**ចប់**